# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ.០០៧៨...... ប្រក.កសក

# ប្រកាស
## ស្តីពី
## ការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ២១៩ប្រក.កសក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែងសម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើដែលមានទីតាំងស្ថិតនៅក្នុងផ្នែករដ្ឋបាលព្រៃឈើស្ទឹងត្រែងនិងផ្នែករដ្ឋបាលព្រៃឈើថាឡាបរិវ៉ាត់នៃខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង ៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះនិងអភិវឌ្ឍព្រៃសហគមន៍ឲ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅទំនៀមទម្លាប់និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាននិងសក្តានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែងនៃប្រកាសនេះមានប្រាំមួយ (៦) សហគមន៍ព្រៃឈើ ចែកចេញជាប្រាំមួយកន្លែងដែលមានផ្ទៃដីសរុបចំនួន១៤៨៣៨(មួយម៉ឺនបួនពាន់ប្រាំបីរយសាមសិបប្រាំបី)ហិកតាដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និងជាប្រព័ន្ធខ្សែព្រំបិទជិតកំណត់ដោយចំណុចគោលនិងនិយាមកាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ។ ក្នុងករណីមានការចាំបាច់ព្រំប្រទល់ព្រៃសហគមន៍ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះអាចកែសម្រួលបានតាមការជាក់ស្តែង។

**ប្រការ ៤.-**

ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

**ប្រការ ៥.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្មខេត្តស្ទឹងត្រែង ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣

**រដ្ឋមន្ត្រី**

**ជ័ន្ទ.សារុន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តស្ទឹងត្រែង
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ៖ ភ្ជាប់ប្រកាសលេខ...០៧៧...ប្រកសកស ចុះថ្ងៃទី ១៩... ខែ...កុម្ភៈ... ឆ្នាំ...២០១៣



ឧបសម្ព័ន្ធ ២ ៖ភ្ជាប់ប្រកាសលេខ ១៧៧...... ប្រក.កសក ចុះថ្ងៃទី ១៩......ខែ មេសា........ឆ្នាំ ២០១៣.....

## ទីតាំងព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែង

| លរ | ឈ្មោះសហគមន៍ព្រៃឈើ | ផ្ទៃដី (ហិកតា) | ចំណុចនិយាមការ ទីតាំងព្រៃសហគមន៍ | | | | ចំនួនភូមិ | ឈ្មោះឃុំ | ឈ្មោះស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | បុរីអូរស្វាយ | ៤៣៨៣ | 608965- 1532007 | 613055-1522998 | 612025-1520510 | | ៥ | អូរស្វាយ | ថាឡាបរិវ៉ាត | ស្ទឹងត្រែង |
| | | | 612997-1532064 | 611968-1523055 | 6J9022-1520510 | | | | | |
| ២ | អ្នកតាកាកាន់ | ២០៣១ | 648994-1504018 | 652539-1507718 | 648534-1504211 | 640977-1503587 | ២ | ស្រែគរ | សេសាន | ស្ទឹងត្រែង |
| | | | 650994-1504018 | 650740-1505765 | 647255-1503707 | 640996-1502016 | | | | |
| | | | 653755-1506260 | 650124-1505563 | 643921-1503287 | 649002-1502020 | | | | |
| ៣ | ភ្នំមៀត | ៥៤៦ | 610135-1519923 | 611994-1515977 | 611718-1515031 | | ១ | កោះស្នែង | ថាឡាបរិវ៉ាត់ | ថាឡាបរិវ៉ាត់ |
| | | | 611994-1520101 | 612207-1515222 | | | | | | |
| ៤ | ជាំពេជ្រ | ២៨៧៥ | 603922-1520249 | 602888-1517977 | 606173-1515947 | 605657-1511412 | ៣ | កោះស្នែង | ថាឡាបរិវ៉ាត់ | ថាឡាបរិវ៉ាត់ |
| | | | 601718-1519097 | 603439-1517459 | 605754-1515805 | 605621-1510699 | | | | |
| | | | 601957-1518640 | 604569-1516600 | 605515-1514510 | 605489-1510017 | | | | |
| | | | 602392-1518210 | 605201-1516322 | 605262-1513685 | | | | | |
| | | | 608599-1509171 | 607987-1515995 | 605266-1512993 | | | | | |
| ៥ | អូរចាប | ២៥៧២ | 621000-1494000 | 622946-1491094 | 620431-1490913 | 617570-1493410 | ៤ | កំភុន | សេសាន | ស្ទឹងត្រែង |
| | | | 623000-1494000 | 622948-1490007 | 620390-1490129 | | | | | |
| | | | 626000-1491094 | 622099-1490118 | 617000-1490000 | | | | | |
| | | | 619000-1493000 | 622044-1490800 | 616000-1493000 | | | | | |
| ៦ | សាមគ្គី | ២៤៣១ | 596609-1468978 | 599935-1467937 | 601745-1463480 | | ៣ | សៀមបូក | សៀមបូក | ថាឡាបរិវ៉ាត់ |
| | | | 598510-1467575 | 599686-1464634 | 596564-1460177 | | | | | |
| | សរុប | ១៤៨៣៨ | | | | | ១៨ | ៥ | ៣ | ២ |


604000
606000
608000
610000
612000
614000
616000
618000
1520000
1522000
1524000
1526000
1528000
1530000
1532000
611968
1523055
609022
1520510
Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960
1:78,000
0 1.25 2.5
Kilometers


642000
644000
646000
648000
650000
652000
654000
1500000
1502000
1504000
1506000
1508000
1510000
Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960
1:58,000
1.25
2.5
Kilometers



608000
609000
610000
611000
612000
613000
614000
1515000
1516000
1517000
1518000
1519000
1520000
Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960
1:37,000
0 0.25 0.5 1 Km


Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960
1:71,000
0 1.25 2.5
Kilometers


Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960
1:56,000
0 0.5 1 2 Km
616000 618000 620000 622000 624000 626000
1488000 1490000 1492000 1494000 1496000


Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960
1:56,000
0 1,000 2,000
Meters
594000 596000 598000 600000 602000 604000
1460000 1462000 1464000 1466000 1468000